CITY OF LONG BEACH PUBLIC NOTICE

**ការជូនដំណឹងជាសាធារណៈ**

ថ្ងៃទី ៧ ខែកក្កដាឆ្នាំ ២០២០

# ការរាយការណ៍ពីករណីឆ្លងមេរោគ West Nile នៅឡុងប៊ិច

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - សប្តាហ៍នេះមានរាយការណ៍ថាករណីដំបូងនៃមនុស្សឆ្លងមេរោគ West Nile (WNV) នៅរដូវមូសនេះបានកើតមាននៅឡុងប៊ិច។ អ្នកជំងឺមានអាយុខ្ទង់ 60 ឆ្នាំហើយត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានការប៉ះពាល់ដល់សរសៃនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

វេជ្ជបណ្ឌិត Anissa Davis បាននិយាយថា "ខណៈពេលដែលពិភពលោកផ្តោតការយកចិត្តទុកដាក់លើការការពារនិងការឆ្លើយតបទៅនឹងជម្ងឺ COVID-19 ហេតុការនេះគឺជាការរំឭកដ៏សំខាន់មួយក្នុងការដែលយើងបន្តឃើញករណីមេរោគ West Nile ស្ទើរតែរៀងរាល់ឆ្នាំនៅឡុងប៊ិច។ យើងមិនអាចបន្ថយការការពាររបស់យើងពីជំងឺឆ្លងពីមូសទេ។"

ករណីមេរោគ West Nile នៅឡុងប៊ិចគ្រាន់តែជាករណីទី 2 ដែលត្រូវបានរាយការណ៍នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាក្នុងឆ្នាំនេះគឺដែលមានបន្ទាប់ពីករណីមនុស្សឆ្លងដំបូងនៃរដូវមូសនេះត្រូវបានរាយការណ៍ថាមាននៅខោនធី Stanislaus County។ រហូតមកដល់ពេលនេះមិនមានមូសនៅឡុងប៊ិចដែលត្រូវបានរកឃើញថាមានមេរោគ West Nile នៅឡើយទេ។

មេរោគ West Nile ឆ្លងតាមរយៈការខាំរបស់មូសប្រភេទ Culex ដែលមានជម្ងឺឆ្លងនេះ។ រោគសញ្ញារបស់មេរោគ West Nile អាចរួមមានគ្រុនក្តៅឈឺខ្លួនឡើងកន្ទួលក្អួតចង្អោរនិងឈឺក្បាល។ មនុស្សភាគច្រើនដែលឆ្លងរោគនេះមិនមានរោគសញ្ញាអ្វីឡើយ។ ប៉ុន្តែប្រមាណជាម្នាក់ក្នុងចំណោម 150 នាក់អាចវិវត្តទៅជាជំងឺធ្ងន់ធ្ងរដូចជាជំងឺរលាកខួរក្បាលឬខ្វិន។ អ្នកដែលមានរោគសញ្ញាទាំងនេះគួរតែស្វែងរកការព្យាបាលជាបន្ទាន់។

មន្ត្រីសុខាភិបាលក្រុងឡុងប៊ិចបានណែនាំដល់ប្រជាពលរដ្ឋអោយអនុវត្តនូវការប្រុងប្រយ័ត្នដូចខាងក្រោម៖

- ការពារការមូសខាំដោយលាបថ្នាំកម្ចាត់សត្វល្អិតជាមួយគ្រឿងផ្សំដែលចុះក្នុងបញ្ជីរបស់ភ្នាក់ងារការពារបរិស្ថានដូចជា DEET, picaridin, IR3535 ឬក្រូចឆ្មាមុនពេលដែលលោកអ្នកចេញទៅខាងក្រៅ។
- សូមពាក់អាវដៃវែងនិងខោជើងវែងប្រសិនបើលោកអ្នកចំណាយពេលនៅខាងក្រៅនៅពេលព្រលឹមនិងព្រលប់។ មូសដែលមានមេរោគ West Nile គឺសកម្មបំផុតក្នុងអំឡុងពេលទាំងនោះ។
- តំឡើងឬជួសជុលរនាំងទ្វារនិងរនាំងបង្អួច។
- ចាក់ទឹកនៅក្នុងធុងឬផើងនៅជុំវិញផ្ទះចោល។
- រាយការណ៍អំពីកន្លែងដែលមានមូសច្រើនដោយចូលទៅកាន់គេហទំព័រ www.longbeach.gov/mosquitoes។
- រាយការណ៍អំពីបក្សីដែលងាប់ដោយប្រើប្រព័ន្ធអ៊ីនធឺណេត។ សូមចូលទៅកាន់គេហទំព័រ http://www.westnile.ca.gov/។

កម្មវិធីបង្ក្រាបវ៉ិចទ័ររបស់ក្រសួងសុខាភិបាលនិងសេវាមនុស្សនៃទីក្រុងឡុងប៊ិចរួមជាមួយភ្នាក់ងារដៃគូគឺសង្កាត់បង្ក្រាបវ៉ិចទ័រនៃខោនធី Los Angeles និងសង្កាត់កម្ចាត់មូសនៃ Compton Creek នឹងបន្តធ្វើការកម្ចាត់មូសនៅតំបន់ដែលមានមូសច្រើនជាងគេនៅទូទាំងទីក្រុងទីក្រុងឡុងប៊ិចជារៀងរាល់ថ្ងៃ។ នៅពេលភ្នាក់ងារទាំងនេះកំពុងធ្វើគ្រប់យ៉ាងដែលអាចធ្វើទៅបានដើម្បីគ្រប់គ្រងចំនួនមូសសាធារណៈជននៅតែមានតួនាទីសំខាន់ក្នុងការបញ្ឈប់មូសពីការបង្កាត់ពូជនៅក្នុងនិងជុំវិញផ្ទះនិងរាយការណ៍អំពីការបង្កាត់ពូជនៅតាមសង្កាត់និងតំបន់សាធារណៈផ្សេងៗ។

សម្រាប់ព័ត៌មានបន្ថែមអំពីមេរោគ West Nile សូមចូលទៅកាន់គេហទំព័រ www.longbeach.gov/wnv។

ការសាកសួរពីសារព័ត៌មានអាចបញ្ជូនទៅអ្នកស្រី Jennifer A. Gonzalez, អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទំនាក់ទំនងអំពីហានិភ័យ, ក្រសួងសុខាភិបាលនិងសេវាប្រជាជន, jennifer.gonzalez@longbeach.gov។

# # #